**សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា**
**Cambodia Microfinance Association**

លេខ: ០៧៦ /២០១៧ ស.ម.ក

# សេចក្តីជូនដំណឹង

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដែលជាតំណាងឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទចំនួន៨៧ ដែលកំពុងធ្វើប្រតិបត្តិការនៅគ្រប់រាជធានី-ខេត្ត មានកិត្តិយសសូមជម្រាបជូនដល់សមាជិក គ្រឹះស្ថានជាដៃគូ និងសាធារណជន មេត្តាជ្រាបដូចខាងក្រោម៖

១. សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាលើកកម្ពស់ការអនុវត្ត **ក្រមស្តីពីការផ្តល់ឥណទានប្រកបដោយសមធម៌** ក្នុងគោលបំណងបំពេញបន្ថែមនូវប្រតិបត្តិការប្រកបដោយវិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់របស់គ្រឹះស្ថានជាសមាជិក ជាពិសេសចូលរួមអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ សេចក្តីណែនាំនិងគោលនយោបាយនានាដែលដាក់ចេញដោយរាជរដ្ឋាភិបាល សំដៅពង្រឹងប្រព័ន្ធហិរញ្ញវត្ថុនិងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់មិនអាចទទួលយកនូវអត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ (ដែលជាប្រភេទលិខិតយថាភូតចេញដោយអាជ្ញាធរមានសមត្ថកិច្ចសម្រាប់បញ្ជាក់អត្តសញ្ញាណបុគ្គល) សម្រាប់ជាវត្ថុធានាក្នុងការផ្តល់ឥណទាននោះឡើយ។

៣. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ជាគ្រឹះស្ថានឯកជនសុទ្ធសាធ និងធ្វើប្រតិបត្តិការសំដៅទទួលបានប្រាក់ចំណេញ ហើយអតិថិជនដែលទទួលប្រាក់កម្ចីត្រូវមានកាតព្វកិច្ចសងត្រឡប់តាមកិច្ចសន្យាកំណត់។

៤. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាស្ថាប័នពាណិជ្ជកម្មនិងមិនមែនជាអង្គភាពនយោបាយនោះទេ។ បុគ្គលិកនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនអាចប្រើប្រាស់ស្លាកសញ្ញានានារបស់គ្រឹះស្ថាន ឬផ្នែកណាមួយនៃប្រតិបត្តិការផ្តល់សេវាជាមូលដ្ឋានក្នុងការចូលរួមសកម្មភាពឬការឃោសនានយោបាយនោះឡើយ។ បុគ្គលិកដែលត្រូវបានរកឃើញថាបានប្រព្រឹត្តល្មើសនឹងគោលការណ៍នេះ នឹងទទួលពិន័យធ្ងន់ធ្ងរបំផុត។

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាសង្ឃឹមយ៉ាងមុតមាំថា សមាជិកទាំងអស់ គ្រឹះស្ថានជាដៃគូ និងសាធារណជន មេត្តាទទួលជ្រាបជាព័ត៌មាននិងចូលរួមសហការផ្សព្វផ្សាយតាមគ្រប់លទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧

**សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា**

លេខ៣០៧ ផ្លូវ៥២ សង្កាត់ ទឹកល្អក់ទី ៣ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ៨៨២ ៦៣៦ អ៊ីម៉ែល: info@cma-network.org គេហទំព័រ: www.cma-network.org